01573562

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារលេខ D309/2/1/7

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៩)

**<u>អង្គបុរេជំនុំជម្រះ</u>**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គីមសាន ជាប្រធាន
ចៅក្រម Oliver BEAUVALLET
ចៅក្រម នីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 06 / 2018
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**កាលបរិច្ឆេទ:** ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០១៨

---

**សាធារណៈ:**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ)**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី អ៊ឹម ចែម**
ប៊ិត ស៊ាងលីម
Wayne JORDASH

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ (សំអាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)"* ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យអង្គបុរេជំនុំជម្រះកែប្រែដីកាសម្រេចកោសលុបសំណៅសាធារណៈនៃដីកាដំណោះស្រាយ (សំអាងហេតុ) របស់សហចៅក្រមស៊ើបអង្កេត ("ដីកាសម្រេចដែលរងការជំទាស់")[2] អនុលោមតាមវិធាន ៧៣ និង ៧៤ នៃវិធានផ្ទៃក្នុង ឬតាមជម្រើសផ្សេងពីនេះ អនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ និងការដាក់ឯកសារ ស្នើសុំឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈចំពោះដីកាដំណោះស្រាយ (សំអាងហេតុ) ដែលដាក់ថាសម្ងាត់ ព្រមទាំងដីកាសម្រេចដែលរងការជំទាស់ បណ្តឹងឧទ្ធរណ៍ និងរាល់ចម្លើយតប[3] ដោយមានការកោសលុបតែចំណុចចាំបាច់ អនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ ("សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ")។

## II. ប្រវត្តនីតិវិធី

[1] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៤/១") បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ (សំអាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D309/2/1/2 ("បណ្តឹងឧទ្ធរណ៍")។

[2] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D309/2 ("ដីកាសម្រេចដែលរងការជំទាស់")។

[3] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២, ៦៤, ៦៦។

២. នៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើមួយស្នើសុំ *ក្នុងចំណោមប្រការផ្សេងទៀត* ឱ្យដាក់សំអាងហេតុនៃដីកាដំណោះស្រាយជាសាធារណៈ[4] ហើយសហមេធាវីការពារក្តី អ៊ឹម ចែម ("សហមេធាវី") បានឆ្លើយតបនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧[5]។

៣. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ[6] ជាសំណៅសម្ងាត់ និងសំណៅកោសលុបជាសាធារណៈ ដោយរក្សាការសម្ងាត់ចំពោះខ្លឹមសារនៃបទចោទ។

៤. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចដែលរងការជំទាស់ ដោយប្រកាស *ក្នុងចំណោមប្រការផ្សេងទៀត* ថាសំណើសុំចេញសំណៅជាសាធារណៈដោយមានការកោសលុបនៃដីកាដំណោះស្រាយ (សំអាងហេតុ) ទុកជាមោឃៈ។

៥. នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលរងការជំទាស់[7] ហើយនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧ បានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់គាត់[8]។

---

[4] សំណុំរឿង ០០៤/១ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីសំអាងហេតុនៃដីកាដំណោះស្រាយនិងដីកាសម្រេចរបស់ ស.ច.ស ត្រូវធ្វើឡើងជាសាធារណៈ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D309។

[5] សំណុំរឿង ០០៤/១ ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សេចក្តីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D309/1។

[6] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3 ("ដីកាដំណោះស្រាយ (សំអាងហេតុ)")។

01573565



៦. សហមេធាវីបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ("ចម្លើយតប")[9] ហើយសហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការឆ្លើយតបនៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៧ ("ការឆ្លើយតប")[10]។

៧. នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៨ អនុលោមតាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ[11] អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានផ្តល់ជូននូវព័ត៌មានពាក់ព័ន្ធនឹងជនរងគ្រោះដែលបានស្នើសុំវិធានការការពារនៅក្នុងសំណុំរឿង ០០៤/១[12]។ នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨ អនុលោមតាមសេចក្តីបង្គាប់លើកទីពីររបស់អង្គបុរេជំនុំជម្រះ[13] សហចៅក្រមស៊ើប

---

[7] សំណុំរឿង ០០៤/១ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំសំអាងហេតុនៃដីកាដំណោះស្រាយធ្វើឱ្យទៅជាសាធារណៈ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D309/2/1។

[8] សូមមើល យោងខាងលើ ជើងទំព័រ ១។

[9] សំណុំរឿង ០០៤/១ ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D309/2/1/3("ចម្លើយតប")។

[10] សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D309/2/1/4("ការឆ្លើយតប")។

[11] សំណុំរឿង ០០៤/១ ដីកាបង្គាប់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារ D309/2/1/5។

[12] សំណុំរឿង ០០៤/១ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ អនុស្សរណៈស្តីពីការវាយតម្លៃអំពីហានិភ័យ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារ D309/2/1/5/1 ("អនុស្សរណៈរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ") រួមជាមួយនឹងឧបសម្ព័ន្ធ ឯកសារ D309/2/1/5/1.1 និង D309/2/1/5/1.2។

[13] សំណុំរឿង ០០៤/១ ដីកាបង្គាប់លើកទីពីរពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារ D309/2/1/6.។

អង្កេតបានផ្តល់ជូននូវព័ត៌មានពាក់ព័ន្ធនឹងបុគ្គលដែលស្ថិតក្រោមវិធានការការពារនៅក្នុងសំណុំរឿង ០០៤/១[14]។

## III. ភាពអាចទទួលយកបាន

៨. សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ស្របតាមវិធាន ៧៣ និង ៧៤ នៃវិធានផ្ទៃក្នុង[15] អនុលោមតាមពេលវេលាកំណត់ដែលមានចែងនៅក្នុងវិធាន ៧៥(១) និង (៣)។ ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថាបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

៩. សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ បានដាក់ស្របតាមមាត្រា ៩ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ("សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ") និងមាត្រា ៣.១២ និង ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")[16]។

១០. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមមាត្រា ៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ ឯកសារអាចត្រូវចាត់ប្រភេទសារឡើងវិញ អនុលោមតាមបទបញ្ជារបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប។ អនុលោមតាមមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ "តាមករណីសមស្រប ទាល់តែមានការចេញដីកាដំណោះស្រាយ និងសេចក្តីសម្រេចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ទើបសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវពិនិត្យពិចារណាថាតើចំណាត់ប្រភេទឯកសារដែល

---

[14] សំណុំរឿង ០០៤/១ ចម្លើយតបទៅនឹងសេចក្តីបង្គាប់របស់ អ.ប.ជ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៨, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារ D309/2/1/6/1 ("អនុស្សរណៈរបស់ ក.ស.ច.ស") រួមជាមួយនឹងឧបសម្ព័ន្ធ ឯកសារ D309/2/1/6/1.1 និង D309/2/1/6/1.2។

[15] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១។

[16] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២។

បានស្នើសុំនោះមានលក្ខណៈសមស្របដែរឬទេ ហើយបើសិនជាមិនសមស្របទេ ត្រូវធ្វើសេចក្តីសម្រេចថាតើចំណាត់ប្រភេទអ្វីទើបសមស្រប"។ មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចែងបន្ថែមទៀតថា "តម្រូវតាមផលប្រយោជន៍យុត្តិធម៌" អង្គជំនុំជម្រះដែលគ្រប់គ្រងសំណុំរឿង អាចដាក់ចំណាត់ប្រភេទឯកសារជាថ្មី។ ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថាខ្លួនមានយុត្តាធិការចម្បង[17] ក្នុងការសម្រេចទៅលើសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ និងយល់ឃើញថាសំណើសុំនេះអាចទទួលយកបាន។

## IV. អង្គសេចក្តី

### ក. អំណះអំណាង

១១. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ការកោសលុបទាំងស្រុងនូវសំអាងហេតុនៃខ្លឹមសារបទចោទប្រកាន់ងនឹង អ៊ឹម ចែម គឺមិនគ្រប់គ្រាន់ដើម្បីក្តោបលើភាពសំខាន់ចាំបាច់ដែលមានលក្ខណៈជាបទដ្ឋាននៃការចូលពិនិត្យមើលឯកសារយ៉ាងពេញលេញជាសាធារណៈនោះឡើយ[18]។ ដោយសារមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អន្តរជាតិ និងសាធារណជន ទៅលើកិច្ចស៊ើបសួរអស់រយៈពេលជា "ច្រើនឆ្នាំ" ការកោសលុបយ៉ាងច្រើនសន្ធឹកសន្ធាប់អាចនាំឱ្យមានការយល់ច្រឡំពីសាធារណជនចំពោះការរកឃើញ និងសេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ (សំអាងហេតុ)[19]។ ហេតុនេះ គាត់ស្នើសុំឱ្យចាត់ចំណាត់ថ្នាក់ឡើងវិញជាឯកសារសាធារណចំពោះដីកាសម្រេចដែលរងការជំទាស់នោះ។ ដូច្នេះ គាត់ស្នើសុំឱ្យចាត់ចំណាត់ថ្នាក់

---

[17] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៣") (អបជ ២៤) សេចក្តីសម្រេចលើសំណើរបស់ មាស មុត ស្នើសុំឱ្យចាត់ចំណាត់ឯកសារ ឡើងវិញជាសាធារណៈនូវសំណើសុំការពិចារណាមួយចំនួនរបស់មេធាវីការពារក្តី ដែលបានដាក់ជូនអង្គជំនុំជម្រះ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D147/1 កថាខណ្ឌ ៥។

[18] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៦។

[19] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៤-១៧។

ឡើងវិញជាសាធារណៈចំពោះដីកាសម្រេចដែលរងការជំទាស់ ព្រមទាំងបណ្តឹងឧទ្ធរណ៍របស់គាត់ និងរាល់ចម្លើយតប ដោយមានការកោសលុបសមស្របចំពោះសាក្សី[20]។

១២. ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា គោលការណ៍ដ៏លើសលុបនៅចំពោះមុខ អ.វ.ត.ក គឺតម្លាភាពជាអតិបរមា ដោយមានករណីលើកលែងដែលមានកម្រិតនៅក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុង ខណៈដែលកិច្ចស៊ើបសួរត្រូវបានដំណើរការ[21]។ ដោយសារវិធានផ្ទៃក្នុងមិនបានចែងឱ្យបានច្បាស់ ឬក៏ហាមឃាត់មិនឱ្យមានការចេញផ្សាយជាសាធារណៈនៃដីកាដំណោះស្រាយ[22] ការពិចារណាត្រូវផ្តោតទៅលើការនិយមចូលចិត្តខ្លាំងជាទូទៅនូវតម្លាភាព ដែលមានចែងនៅក្នុងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង ព្រមទាំងនៅក្នុងវិធាន ២១(១) និង ២១(១)(គ), ២៩(៤)(ង), ៧៩(៦), ១០៩(១), ៧៩(៦)(ឃ) និងវិធាន ១០២ នៃវិធានផ្ទៃក្នុង[23], យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[24] និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល[25]។ លើសពីនេះទៀត មាត្រា ៨៣(៤) និង ១២១(៥) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលបានដកស្រង់មកធ្វើជាសំអាង ព្រមទាំងការយោងសំអាងទៅលើផ្នែកនានាដែលបានដកស្រង់នៃក្រមព្រហ្មទណ្ឌ

---

[20] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៤។

[21] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២០-២១។

[22] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤។

[23] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤-៣០។

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៨ ដែលយោងទៅលើសំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រី អ៊ឹម ចែម ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ មតិយោបល់របស់ចៅក្រម BEAUVALLET និង BWANA ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ២-៤។

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១-៣២ ដែលយោងទៅលើរឿងក្តីលេខ ០០១/១៨-០៧-២០០៧-អវតក/អជតក ("សំណុំរឿង ០០១") សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ F30/2 កថាខណ្ឌ ៥-៦។ សំណុំរឿង ០០១ សាលដីកា ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៧០៨។



PRE-TRIAL CHAMBER E.C.C.C.

អាល្លឺម៉ង់ (ផ្នែក ៣៥៣យ), ក្រមព្រហ្មទណ្ឌស្វីស (មាត្រា ២៩៣) និងក្រមព្រហ្មទណ្ឌបារាំង (មាត្រា ២២៦-១៣) ពាក់ព័ន្ធទៅនឹងការរំលោភលើដីកាបង្គាប់រក្សាការសម្ងាត់នៅក្នុងអំឡុងពេលកិច្ចស៊ើបសួរ មិនមែនពាក់ព័ន្ធទៅនឹងការចេញផ្សាយជាសាធារណៈនូវដីកាដំណោះស្រាយនៅពេលកិច្ចស៊ើបសួរបានបញ្ចប់នោះឡើយ[26]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានយោងបន្ថែមទៀតទៅលើច្បាប់អន្តរជាតិ ដែលក្នុងនោះរួមមាន មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("កតិកាសញ្ញាអន្តរជាតិ"), មាត្រា ៦(១) នៃអនុសញ្ញាអឺរុបស្តីពីសិទ្ធិមនុស្ស ព្រមទាំងលក្ខន្តិកៈ វិធាន និងច្បាប់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ និងតុលាការដែលមានលក្ខណៈជាតុលាការអន្តរជាតូបនីយកម្មនានា ដែលតម្លាភាពមាន "សារៈសំខាន់ខ្លាំង" នៅចំពោះមុខតុលាការទាំងនេះ ក្នុងការកសាងទំនុកចិត្តសាធារណៈ និងការបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រ[27]។

១៣. ចំណុចទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានផ្តល់សំអាងហេតុសមហេតុផលចំពោះការកោសលុប[28] ដោយធ្វើការពន្យល់ត្រឹមតែតាមរយៈសេចក្តីប្រកាសព័ត៌មានចំនួនពីរលើកអំពីការកោសលុបនេះ ថា ការធ្វើដូច្នេះគឺដោយសារដីកាដំណោះស្រាយ មានលក្ខណៈពិសេសជាដីកាលើកលែងការចោទប្រកាន់ និងដោយសារសច្ចធារណ៍និរទោសរបស់ អ៊ឹម ចែម និងសិទ្ធិបុគ្គលភាព[29]។

---

[26] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧ ដែលយោងទៅលើដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦។ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៨-៥១ ដែលយោងទៅលើដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ១៦ និងជើងទំព័រ ២០។

[27] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣-៤២។

[28] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣-កថាខណ្ឌ ៤៦។

[29] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤-កថាខណ្ឌ ៤៥ *យោងលើ* សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក "សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម" ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧។ សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក "សហចៅក្រមស៊ើបអង្កេត ចេញសំអាងហេតុស្តីពីការលើកលែងការចោទប្រកាន់ក្នុងសំណុំរឿង ០០៤/០១" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧។

១៤. ចំណុចចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា វិធានផ្ទៃក្នុង និងគោលការណ៍សច្ចធារណ៍និរទោស ពុំទាមទារលក្ខខណ្ឌថា ភ័ស្តុតាងទាំងអស់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ ត្រូវបង្ហាញជូនសាធារណជននៅក្នុងពេលជំនុំជម្រះទាំងមូលនោះទេ[30] ហើយវាពុំផ្តល់សិទ្ធិដោយឯកឯង ឱ្យដកហូតព័ត៌មានពីសាធារណជន ដើម្បីការពារកិត្តិយសរបស់ជនសង្ស័យនោះទេ[31]។ លើសពីនេះ អ៊ឹម ចែម ត្រូវបានសាធារណជនស្គាល់ថាជាបុគ្គលត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចំពោះមុខ អ.វ.ត.ក[32] រួចហើយ រួមទាំងតាមរយៈសេចក្តីថ្លែងការណ៍របស់សហមេធាវីរបស់គាត់ផ្ទាល់ផងដែរ[33]។

១៥. សហមេធាវីឆ្លើយតបថា សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានអនុវត្តបទដ្ឋានត្រឹមត្រូវនៃការសើរើបណ្តឹងឧទ្ធរណ៍ និងកំណត់មូលដ្ឋានបណ្តឹងឧទ្ធរណ៍ ឬ កំហុសអង្គច្បាប់ និង/ឬ អង្គហេតុ ផ្ទុយទៅវិញ បែរជាស្នើសុំឱ្យពិចារណាឡើងវិញលើដីកាសម្រេចដែលរងការជំទាស់ទៅវិញ[34]។ សហមេធាវីអះអាងថា ការរក្សាការសម្ងាត់នៃការស៊ើបអង្កេតគឺជានិយាមមួយ[35]។ ប្រព័ន្ធច្បាប់ស៊ីវិលឡក្នុងស្រុក ក៏គាំទ្រវិធីសាស្ត្រប្រកបដោយភាពប្រុងប្រយ័ត្នចំពោះការរក្សាការសម្ងាត់លើការស៊ើបអង្កេត ដែលនៅបន្តអនុវត្តទោះពេលបញ្ចប់កិច្ចស៊ើបសួររួចហើយក៏ដោយ ជាទូទៅ បានបញ្ចប់ក្រោយ ពេលអង្គបុរេជំនុំជម្រះបានចេញសាលដីកា សម្រេចលើបណ្តឹងឧទ្ធរណ៍[36]។ នៅក្នុងអំឡុងពេលស៊ើបអង្កេត សាធារណជនពុំមានសិទ្ធិ ទទួលបាន

---

[30] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥២-កថាខណ្ឌ ៦២។

[31] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៤។

[32] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៥-កថាខណ្ឌ ៥៩។

[33] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧ *យោងលើ* កាសែតភ្នំពេញប៉ុស្តិ៍ "សេចក្តីសម្រេចលើ Lauds ដែលជាមេធាវីការពារក្តី អ៊ឹម ចែម" ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧។

[34] ចម្លើយតប កថាខណ្ឌ ២២-កថាខណ្ឌ ២៤។

[35] ចម្លើយតប កថាខណ្ឌ ៣១-កថាខណ្ឌ ៣២។

[36] ចម្លើយតប កថាខណ្ឌ ៣៥ កថាខណ្ឌ ៣៨-កថាខណ្ឌ ៣៩។

ការជូនដំណឹងអំពីលទ្ធផលនៃរឿងក្តីនោះឡើយ ហើយ អ.វ.ត.ក ក៏ពុំមានតួនាទីនៅ ក្នុងការបង្កើតប្រវត្តិសាស្ត្រនោះដែរ[37]។

១៦. សហមេធាវីអះអាងថា ដោយសារគ្មានឱកាសតវ៉ាការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ពីព្រោះលក្ខណៈពិសេសរបស់វា[38] អ៊ឹម ចែម គួរទទួលបានការការពារបន្ថែមលើភាពឯកជន និងកិត្តិយសរបស់ខ្លួន ដោយសារការតាមដានពីសារព័ត៌មាន ដែលគាត់ទំនងប្រឈម[39]។ ចំណុចចុងក្រោយ នៅពេលពិចារណាថា សហចៅក្រមស៊ើបអង្កេតគ្មានយុត្តាធិការ សហមេធាវីអះអាងថា ការរកឃើញទាំងអស់ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ត្រូវបានធ្វើឡើងហួសដែនអំណាចរបស់ខ្លួន ដូច្នេះ តម្រូវឱ្យមានការកោសលុប[40] ហើយសហមេធាវីស្នើសុំការកែប្រែលើសំណៅជាសាធារណៈនៃដីកាដំណោះស្រាយ[41]។ ដូច្នេះ សហមេធាវីស្នើសុំអង្គបុរេជំនុំជម្រះ ច្រានចោលបណ្តឹងឧទ្ធរណ៍ ប៉ុន្តែស្នើសុំឱ្យអនុញ្ញាត តាមសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញលើដីកាសម្រេចដែលរងការជំទាស់ ចំពោះបណ្តឹងឧទ្ធរណ៍ និងចម្លើយតបរបស់ពួកគេ ហើយនឹងសំណើកែប្រែជាសំណៅកោសលុបនៃដីកាដំណោះស្រាយ (សំអាងហេតុ) មកជាសាធារណៈវិញ[42]។

១៧. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងសាជាថ្មីនៅក្នុងការឆ្លើយតបរបស់ខ្លួនថា ការរក្សាការសម្ងាត់នៃការស៊ើបអង្កេតចាំបាច់ ត្រូវធ្វើឡើងនៅក្នុងអំឡុងពេលស៊ើបអង្កេតតែប៉ុណ្ណោះ ហើយ

---

[37] ចម្លើយតប កថាខណ្ឌ ៣១-កថាខណ្ឌ ៣៤។

[38] ចម្លើយតប កថាខណ្ឌ ៤៦។

[39] ចម្លើយតប កថាខណ្ឌ ៥៣-កថាខណ្ឌ ៥៨។

[40] ចម្លើយតប កថាខណ្ឌ ៦៣-កថាខណ្ឌ ៦៦។

[41] ចម្លើយតប កថាខណ្ឌ ៦៨-កថាខណ្ឌ ៦៩។

[42] ចម្លើយតប ទំព័រ ២៦។

មិនពាក់ព័ន្ធនៅក្នុងដំណាក់កាលនៃដីកាដំណោះស្រាយនោះឡើយ[43]។ គាត់ក៏បានសន្និដ្ឋានផងដែរថា សច្ចធារណ៍និរទោសរបស់ អ៊ឹម ចែម នឹងពុំមានការរំលោភបំពាននោះទេ តាមរយៈការលាតត្រដាងដីកាដំណោះស្រាយទាំងស្រុង (សំអាងហេតុ)[44] ហើយការភ័យខ្លាចរបស់ អ៊ឹម ចែម អំពីការជំនុំជម្រះតាមរយៈសារព័ត៌មាន និងការរិះគន់ទំនងធ្វើឡើងសំដៅលើមន្ត្រី អ.វ.ត.ក គឺជាការប៉ាន់ស្មាន។ ទោះក្នុងករណីណាក៏ដោយ ព័ត៌មានពុំគួរលាក់បាំងពី សាធារណជន ដោយសារការភ័យខ្លាចមានការរិះគន់នោះឡើយ[45]។ ចំណុចចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិតវ៉ាថា សំណើរបស់សហមេធាវី សុំកែប្រែការកោសលុប គឺជាការប៉ុនប៉ងពុំទាន់ពេលវេលា ដើម្បីប្តឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការកោសលុប[46]។

## ខ. កិច្ចពិភាក្សា

១៨. អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលរងការជំទាស់ ដែលបានចាត់ទុកឥតបានការចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំបញ្ចេញជាសាធារណៈនូវសំអាងហេតុនៃដីកាដំណោះស្រាយទាំងស្រុង (សំអាងហេតុ) និង តាមជម្រើសផ្សេងមួយទៀត សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ ចំពោះដីកាដំណោះស្រាយដោយផ្នែកខ្លះមានការកោសលុប ចំពោះដីកាសម្រេចដែលរងការជំទាស់ ចំពោះបណ្តឹងឧទ្ធរណ៍ និងចំពោះចម្លើយតប។

### ១. ការធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះដីកាដំណោះស្រាយ (សំអាងហេតុ) ឬ ចំពោះផ្នែកដែលត្រូវបានកោសលុប

[43] ការឆ្លើយតប កថាខណ្ឌ ៣-កថាខណ្ឌ ៤ កថាខណ្ឌ ៩។

[44] ចម្លើយតប កថាខណ្ឌ ១២។

[45] ចម្លើយតប កថាខណ្ឌ ១៣-កថាខណ្ឌ ១៤។

[46] ចម្លើយតប កថាខណ្ឌ ១៨-កថាខណ្ឌ ២១។

១៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះដីកាដំណោះស្រាយ (សំអាងហេតុ) គឺជាដំណោះស្រាយចំបងមួយដែលស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិ[47] ហើយអង្គបុរេជំនុំជម្រះនឹងដោះស្រាយបញ្ហានេះមុនគេ។ ការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារទាំងមូល ពុំមានគ្រោះថ្នាក់នោះទេ ដោយសារដីកាដំណោះស្រាយ (សំអាងហេតុ) ត្រូវបានធ្វើចំណាត់ថ្នាក់ជាសាធារណៈរួចហើយ។ ផ្ទុយមកវិញ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញគឺធ្វើឡើងក្នុងគោលបំណងធ្វើចំណាត់ថ្នាក់ឡើងវិញលើផ្នែកកោសលុបនៃដីកាដំណោះស្រាយ (សំអាងហេតុ) តែប៉ុណ្ណោះ។

<u>ក. ការធ្វើជាសាធារណៈ និងវិសាលភាពនៃការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ)</u>

២០. សហព្រះរាជអាជ្ញាអន្តរជាតិតវ៉ាវិសាលភាពនៃការកោសលុបនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) និងអះអាងថា ស្ទើរតែពាក់កណ្តាលនៃដីកាដំណោះស្រាយត្រូវបានកោសលុបនៅក្នុងសំណៅសាធារណៈ រួមទាំង ការវាយតម្លៃទាំងអស់អំពីចំណុចសារធាតុនៃឧក្រិដ្ឋកម្ម និងចំណុចដកស្រង់ចេញពីកំណត់ហេតុនៃការស្តាប់ចម្លើយ ដូចជា ចម្លើយដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី[48]។

២១. អង្គបុរេជំនុំជម្រះសូមរំលឹកថា វិធាន ២១(១) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យមានការបកស្រាយវិធាន និងបទប្បញ្ញត្តិ អ.វ.ត.ក ជាប្រយោជន៍ដល់ជនត្រូវចោទ និងជនរងគ្រោះ ព្រមទាំងគោលការណ៍តម្លាភាពនៃកិច្ចដំណើរការនីតិវិធី។ មាត្រា ១២.២ នៃកិច្ចព្រមព្រៀង គូសបញ្ជាក់បន្ថែមទៀតអំពីសារសំខាន់នៃការផ្សាយជាសាធារណៈ តាមរយៈការផ្តល់សិទ្ធិឱ្យតាមដានកិច្ចដំណើរការនីតិវិធី "នៅគ្រប់ពេលវេលាទាំងអស់" ជូនដល់ "សារព័ត៌មាន" និង "អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ" ។ អញ្ញត្រកម្មលើការផ្សាយជាសាធារណៈនៃកិច្ច

[47] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៦។

[48] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧។

ដំណើរការនីតិវិធី ត្រូវធ្វើឡើងឱ្យស្របតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ "ត្រឹមកម្រិតចាំបាច់ខ្លាំងបំផុត ទៅតាមការយល់ឃើញរបស់អង្គជំនុំជម្រះពាក់ព័ន្ធ និងក្នុងករណីការផ្សាយជាសាធារណៈនឹងប៉ះពាល់ដល់ផលប្រយោជន៍នៃយុត្តិធម៌"[49]។ គ្មានអញ្ញត្រកម្មណាមួយចំពោះគោលការណ៍នៃការផ្សាយជាសាធារណៈអំពីការជំនុំជម្រះ ដូចមានចែងនៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ[50] ឬសំអាងហេតុដែលចេញដោយសហចៅក្រមស៊ើបអង្កេតដែលផ្តល់ដែនកម្រិតលើការផ្សាយដីកាដំណោះស្រាយជាសាធារណៈ។

២២. អង្គបុរេជំនុំជម្រះសូមរំលឹកទៀតថា សេចក្តីសម្រេច ដីកាសម្រេច និងការរកឃើញផ្សេងទៀតរបស់សហចៅក្រមស៊ើបង្កេត ត្រូវរក្សាការសម្ងាត់[51]។ អង្គបុរេជំនុំជម្រះអាចធ្វើចំណាត់ថ្នាក់ឯកសារទាំងនោះជាសាធារណៈឡើងវិញ ប្រសិនបើចាំបាច់ ដោយមានការកោសលុប[52]។ មាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចែងថា "តាមករណីសមស្របទាល់តែមានការចេញដីកាដំណោះស្រាយ និងសេចក្តីសម្រេចប្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ទើបសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវពិនិត្យពិចារណាថាតើចំណាត់ប្រភេទដែលបានស្នើសុំនោះមានលក្ខណៈសមស្របដែរឬទេ ហើយបើសិនជាមិនសមស្របទេត្រូវធ្វើសេចក្តីសម្រេចថាតើចំណាត់ប្រភេទអ្វីទើបសមស្រប"។

---

[49] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១២.២។

[50] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា ១៤។

[51] សេចក្តីណែនាំអនុវត្តស្តីអំពីការធ្វើចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង អ.វ.ត.ក/00៤/២00៩/វិ.លើកទី ២ ("សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ") មាត្រា ៥.១.ច។

[52] សេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ មាត្រា ៤.ច មាត្រា ៩.២ និងមាត្រា ៩.៣។

២៣. ត្រង់ចំណុចលើកឡើងនេះ វិធានផ្ទៃក្នុង និងបទប្បញ្ញត្តិផ្សេងទៀតនៃ អ.វ.ត.ក ពុំផ្តល់ជាគោលការណ៍ណែនាំអំពីការធ្វើចំណាត់ថ្នាក់ដីកាដំណោះស្រាយឡើងវិញ[53] ឬកម្រិតនៃការកោសលុបនោះឡើយ។

២៤. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថាចាំបាច់ត្រូវលើកឡើងអំពីវិសាលភាពនៃការកោសលុបនៅក្នុងដីកាដំណោះស្រាយមុនៗ។ ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង 00១ រួមមាន ១៧១ កថាខណ្ឌ ក្នុងចំនួន ៤៥ ទំព័រ។ សំណៅជាសាធារណៈដែលមានផ្នែកកោសលុប គឺកម្រិតត្រឹមលេខយោងជើងទំព័រ និងឈ្មោះរបស់សាក្សី និងជនរងគ្រោះនៅក្នុងអត្ថបទ។ ឈ្មោះទាំងនោះត្រូវបានជំនួសដោយពាក្យ "សាក្សី" ឬ "បុគ្គល" រួមជាមួយនឹងតួអក្សរកំណត់អត្តសញ្ញាណ[54]។ ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង 00២ មាន ៧៣២ ទំព័រ និង ១៦២៤ កថាខណ្ឌ។ ក្នុងចំណោមកថាខណ្ឌទាំង ១៦២៤ កថាខណ្ឌ ចំនួន ១៦៤ កម្រកោសលុបនៅក្នុងសំណៅសាធារណៈ។ និយាយឱ្យជាក់លាក់ជាងនេះ មានការកោសលុបចំនួន ៤0២ កន្លែង កន្លែងនីមួយៗមានច្រើនបំផុតមួយ ឬ ពីរពាក្យ។ នៅពេលពិនិត្យមើលជើងទំព័រ វាបង្ហាញឱ្យយើងឃើញថា សហចៅក្រមស៊ើបអង្កេតហាក់ដូចជាបានជ្រើសរើសកោសលុបអត្តសញ្ញាណរបស់សាក្សី។ ចំណុចយោងសាមញ្ញមួយរួមមានលេខឯកសារ និងការបង្ហាញលក្ខណៈនៃភស្តុតាងទូទៅ ដូចជា "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី"[55]។

២៥. យើងអាចលើកឡើងយោបល់ពីរពាក់ព័ន្ធនឹងវិសាលភាពនៃការកោសលុបដីកាដំណោះស្រាយមុនៗ។ យោបល់ទីមួយ សំណៅសាធារណៈដែលមានការកោសលុបកម្រិតត្រឹមការកោសលុប

---

[53] ផ្ទុយពីករណីនេះ *សូមមើល* មាត្រា ៥ នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ។

[54] សំណុំរឿង 00១ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២00៨ ឯកសារ D99 (សំណៅកោសលុបសាធារណៈ)។

[55] សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/កសចស ("សំណុំរឿង 00២") ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២0១0 ឯកសារ D427 ("សំណៅកោសលុបសាធារណៈ")។

ឈ្មោះបុគ្គលដែលត្រូវបានស្តាប់ចម្លើយជាសាក្សី ទាំងនៅក្នុងតួអត្ថបទ និងជើងទំព័រ។ យោបល់ទីពីរ សំអាងហេតុ និងសំអាងច្បាប់ ត្រូវបានដកចេញជាលក្ខណៈប្រព័ន្ធពីវិសាលភាពនៃការកោសលុប ហើយត្រូវបានផ្សាយជាសាធារណៈ ទោះបីជាដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ក៏ដោយ។

២៦. បើប្រៀបធៀបទៅ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាដំណោះស្រាយ (សំអាងហេតុ) នៅក្នុងសំណុំរឿង ០០៤/០១ ត្រូវបានកោសលុបច្រើន។ សំណៅសាធារណៈមានចំនួន ៨២ ទំព័រ ចំណែកសំណៅសម្ងាត់មានចំនួន ១៣២ ទំព័រ។ ការកោសលុបមិនត្រឹមលុបចោលតួអត្ថបទនៃសំណៅសាធារណៈចំនួន ១៧ ទំព័រ ប៉ុណ្ណោះទេ វាស្ទើរតែពីរទំព័រពេញស្តីពីចំណងជើង[56] ឈ្មោះជាច្រើន និងចំណុចយោងច្រើនគួរសមដែរ។ អ្វីដែលជាក់លាក់ជាងនេះ ជំពូកពាក់ព័ន្ធនឹងយុត្តាធិការលើ អ៊ឹម ចែម ត្រូវបានគូសខ្មៅទាំងអស់[57]។ វាមានន័យថា ហេតុផលអ្វីដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញថា សហចៅក្រមស៊ើបអង្កេតគ្មានយុត្តាធិការបុគ្គលលើ អ៊ឹម ចែម ពុំបានផ្សាយជាសាធារណៈនោះឡើយ។

<u>ខ. ការធ្វើចំណាត់ថ្នាក់ដីកាដំណោះស្រាយ (សំអាងហេតុ) ឡើងវិញ</u>

២៧. មាត្រា ១.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទចែងថា គោលការណ៍ចាំបាច់នៃការធ្វើចំណាត់ប្រភេទ "គឺជាតម្រូវការទាមទារឱ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ដែលមិនបើកចំហរ

[56] ដីកាដំណោះស្រាយ (សំអាងហេតុ) ទំព័រ ៣-ទំព័រ ៥។

[57] ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣១៣-កថាខណ្ឌ ៣២៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និង សម្រាប់គោលបំណងនៃការអប់រំ និងកេរដំណែល"[58]។

២៨. អង្គបុរេជំនុំជម្រះដឹងអំពីភាពចាំបាច់ត្រូវថ្លឹងថ្លែងផលប្រយោជន៍ខុសៗគ្នាដែលរងប៉ះពាល់ រួមទាំង ផលប្រយោជន៍របស់ជនត្រូវចោទ និង ជនរងគ្រោះ តម្លាភាពនៃកិច្ចដំណើរការនីតិវិធី ដូចមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងផលប្រយោជន៍យុត្តិធម៌។

*i. ផលប្រយោជន៍ជនត្រូវចោទ*

២៩. នៅពេលពិចារណាលើលក្ខណៈពិសេសនៃដីកាលើកលែងការចោទប្រកាន់ សហមេធាវីអះអាងថា ការចេញដីកាដំណោះស្រាយ (សំអាងហេតុ) ជាសាធារណៈ នឹងប៉ះពាល់លើសិទ្ធិរបស់ អ៊ឹម ចែម ទទួលបានការការពារលើជីវិតឯកជន និងកិត្តិយសរបស់គាត់ និងសច្ចធារណ៍និរទោស ដោយក្នុងនោះសំអាងសំខាន់លើមាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិ[59]។

៣០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា កិច្ចព្រមព្រៀង ឬ វិធានផ្ទៃក្នុង គ្មានចែងយោងលើមាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិ ដែលធានាការការពារជីវិតឯកជន កេរ្តិ៍ឈ្មោះ និងកត្តិយសនោះឡើយ[60]។ អង្គបុរេជំនុំជម្រះបានរកឃើញរួចហើយថា ជនត្រូវចោទពុំមាន

---

[58] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ មាត្រា ១.២។ *សូមមើលផងដែរ* សំណុំរឿងលេខ ០០២ (អ.ប.ជ ៥៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ១។

[59] ចម្លើយតប កថាខណ្ឌ ៤៦ កថាខណ្ឌ ៥១ កថាខណ្ឌ ៥៩។

[60] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា ១៧ ("គ្មានបុគ្គលណាម្នាក់ត្រូវបានទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬ ខុសច្បាប់ លើជីវិតឯកជន គ្រួសារ លំនៅដ្ឋាន ឬ លិខិតឆ្លើយឆ្លង ឬ ធ្វើការប៉ះពាល់ដោយខុសច្បាប់លើសេចក្តីថ្លៃថ្នូរ និងកត្តិយសបានឡើយ")។

“សិទ្ធិដែលមានជាប់មកជាមួយ ក្នុងការទទួលបានសុចរិតភាពនៃការអនុវត្តកិច្ចស៊ើបអង្កេត កិច្ចស៊ើបអង្កេតដោយសម្ងាត់ ឬ ការការពារកិត្តិយសរបស់គាត់”[61]។

៣១. ពាក់ព័ន្ធនឹងការការពារសច្ចធារណ៍និរទោស អង្គបុរេជំនុំជម្រះសូមរំលឹកថា ដីកាលើកលែងការចោទប្រកាន់មុនមួយត្រូវបានចេញ ដោយពុំមានការចោទប្រកាន់បុគ្គលមួយរូប ប៉ុន្តែដោយគ្រាន់ត្រឹមតែសង្ស័យប៉ុណ្ណោះ ហើយពុំបានបញ្ចូលការកោសលុបលើខ្លឹមសារនោះទេ ដោយត្រឹមតែកោសលុបចំណុចយោងជើងទំព័រសម្ងាត់មួយចំនួនតូចប៉ុណ្ណោះ[62]។

៣២. ចៃដន្យ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីបានឆ្លៀតលើកយោបល់អំពីដីកាដំណោះស្រាយ (សំអាងហេតុ) ផ្សាយប្រាប់អ្នកសារព័ត៌មានក្រោយពេលដីកានេះចេញរួចហើយនោះ[63]។ អ្វីសំខាន់ជាងនេះ អ៊ឹម ចែម ខ្លួនឯងបានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈនៅក្នុងកិច្ចសម្ភាសន៍ដែលគាត់បានផ្តល់ជូនអ្នកសារព័ត៌មាន[64]។

៣៣. យោងតាមចំណុចលើកឡើងខាងលើ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការខូចខាតបណ្តាលមកពីដីកាលើកលែងការចោទប្រកាន់ ចំពោះសិទ្ធិរបស់ អ៊ឹម ចែម នៅក្នុងការទទួលបានសច្ចធារណ៍និរទោស និងចំពោះកិត្តិយសរបស់គាត់ នៅតែពុំមានភាពជាក់លាក់ ឬ គ្រាន់តែជាសម្មតិកម្មប៉ុណ្ណោះ។

---

[61] សំណុំរឿងលេខ ០០៤ (អ.ប.ជ ២៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47 ឯកសារ D193/49 ឯកសារ D193/51 ឯកសារ D193/53 ឯកសារ D193/56 ឯកសារ និង D193/60 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D284/1/4 កថាខណ្ឌ ២៣។

[62] សំណុំរឿង ០០៣ ការលើកលែងចោទប្រកាន់ប្រឆាំងនឹង ស៊ូ ម៉េត ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D86/3។

[63] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧ *យោងលើ* កាសែតភ្នំពេញប៉ុស្តិ៍ “សេចក្តីសម្រេចលើ Lauds ដែលជាមេធាវីការពារក្តី អ៊ឹម ចែម” ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧។

[64] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៨ *យោងលើ* កាសែតញ៉ូវយ៉កថែម J. WALLACE “ជីវិតជនបទរបស់ជីដូនជនជាប់ចោទកម្ពុជា ចំពោះអំពើសម្លាប់រង្គាល” ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧។



PRE-TRIAL CHAMBER E.C.C.C.

*ii. ផលប្រយោជន៍ជនរងគ្រោះ*

៣៤. អនុលោមតាមវិធាន ២១(១)(គ) "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការការពារក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីរឿងក្តី"។ វិធាន ២៩(១) នៃវិធានផ្ទៃក្នុងចែងបន្ថែមទៀតថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាអំពីកិច្ចការពារដល់អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដូចមានចែងក្នុងកិច្ចព្រមព្រៀងបន្ថែមស្តីពីសន្តិសុខ និងសុវត្ថិភាព និងនៅក្នុងសេចក្តីណែនាំអនុវត្តដទៃទៀត" ដែលគោលបំណងវិធានការការពារត្រូវបានកំណត់នៅក្នុងវិធាន ២៩(៤)[65]។

៣៥. អង្គបុរេជំនុំជម្រះធ្លាប់បានគូសបញ្ជាក់អំពីសារសំខាន់នៃការជូនដំណឹងជនរងគ្រោះ ហើយពិចារណាឃើញថា "ការបង្ហាញពីការយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវក្នុងការប្រព្រឹត្តរបស់សហចៅក្រមស៊ើបអង្កេត គឺជាកត្តាពាក់ព័ន្ធមួយ នៅពេលដែលធ្វើការពិចារណាទៅលើសិទ្ធិរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធី"។ អង្គបុរេជំនុំជម្រះក៏បានសម្រេចបន្ថែមទៀតថា ទោះបីជា "សហចៅក្រមស៊ើបអង្កេតត្រូវបានចងកាតព្វកិច្ច ដោយបទប្បញ្ញត្តិជាក់លាក់មួយចំនួនក្នុងវិធានផ្ទៃក្នុង ទាក់ទងនឹងការរក្សាការសម្ងាត់ នៃការស៊ើបអង្កេត ទើបធ្វើឱ្យមានការរឹតបន្តឹងទៅលើព័ត៌មានដែលសហចៅក្រមស៊ើបអង្កេត អាចជម្រាបជូនដល់សាធារណជន

[65] វិធាន ២៩(៤) នៃវិធានផ្ទៃក្នុង ("ក្នុងបរិបទនេះ សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ អាចចេញសេចក្តីបង្គាប់ដោយមានសំអាងហេតុ ចាត់វិធានការដើម្បីការពារអត្តសញ្ញាណជនទាំងនោះ ដូចជា៖ ក-កំណត់យកអាសយដ្ឋានរបស់សហមេធាវីរបស់ពួកគេ ឬ របស់សមាគមជនរងគ្រោះរបស់ពួកគេ ឬ របស់អង្គជំនុំជម្រះវិសាមញ្ញ ជាអាសយដ្ឋានទំនាក់ទំនងរបស់ពួកគេ តាមករណីសមស្រប។ ខ-ប្រើរហស្សនាមនៅពេលនិយាយសំដៅទៅរកជនត្រូវការពារនោះ គ-អនុញ្ញាតឱ្យធ្វើកំណត់ហេតុសួរយកចម្លើយរបស់ជននោះ ដោយមិនចាំបាច់សរសេរអត្តសញ្ញាណរបស់ជននោះនៅក្នុងសំណុំរឿង។ ឃ-នៅពេលណាជនត្រូវចោទ ឬ ជនសង្ស័យស្នើឱ្យមានការឆ្លើយតទល់គ្នាជាមួយជននោះ គេអាចប្រើប្រាស់បច្ចេកទេសដែលអនុញ្ញាតឱ្យមានការចូលរួមពីចម្ងាយ ឬ បំប្លែងសម្លេងដើម ឬ បិទបាំងភិនភាគរបស់ជននោះ។ ង-ជាករណីលើកលែងចំពោះគោលការណ៍សវនាការជាសាធារណ: អង្គជំនុំជម្រះអាចរៀបចំផ្នែកដំណើរការនីតិវិធីណាមួយជាសម្ងាត់ ឬអនុញ្ញាតឱ្យបង្ហាញភស្តុតាងតាមរយ:ប្រព័ន្ធអេឡិចត្រូនិច ឬ ក៏ប្រើប្រាស់មធ្យោបាយពិសេសៗដទៃទៀត")។

01573580



[...] បទប្បញ្ញត្តិជាក់លាក់ទាំងនោះ គួរត្រូវបកស្រាយគ្រប់ពេលវេលា ដោយភ្ជាប់ជាមួយ បទប្បញ្ញត្តិស្តីពីគោលការណ៍ជាសារវ័ន្តនៃដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដែលតម្រូវឱ្យជូនដំណឹងដល់ជនរងគ្រោះ ព្រមទាំងគោរពដល់សិទ្ធិរបស់ជនរងគ្រោះ នៅក្នុងដំណើរការនីតិវិធី"[66]។

*iii. តម្លាភាពនៃកិច្ចដំណើរការនីតិវិធី និងផលប្រយោជន៍យុត្តិធម៌*

៣៦. អង្គបុរេជំនុំជម្រះសូមរំលឹកឡើងវិញថា ការស៊ើបអង្កេតនៅតែត្រូវរក្សាការសម្ងាត់រហូតដល់ពេលមានការស៊ើបមូល ដើម្បីការពារសុចរិតភាព និងផលប្រយោជន៍របស់ភាគី[67]។ ផលប្រយោជន៍ទាំងនេះគួរត្រូវថ្លឹងថ្លែងជាមួយនឹងភាគចាំបាច់ត្រូវ "ធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"[68]។

៣៧. ដូចបានសម្រេចខាងលើ វិធានផ្ទៃក្នុង និងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ពុំបានផ្តល់ដែនកម្រិតលើការផ្សាយដីកាដំណោះស្រាយជាសាធារណៈនោះឡើយ[69]។ នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ការផ្សាយជាសាធារណៈ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី មានសារសំខាន់នៅក្នុងករណីតម្កល់បទចោទ ឬ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាងការលើកលែងការចោទប្រកាន់លើបទចោទ[70]។

---

[66] សំណុំរឿងលេខ ០០២ (អ.ប.ជ ៧៣-អ.ប.ជ១៧១) សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៥១-៥២។

[67] វិធាន ៥៦ នៃវិធានផ្ទៃក្នុង។ *សូមមើល* កថាខណ្ឌ ២២ ខាងលើ។

[68] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[69] *សូមមើល* កថាខណ្ឌ ២១ ខាងលើ។

[70] សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក "សហចៅក្រមស៊ើបអង្កេតចេញសំអាងហេតុអំពីការលើកលែងការចោទប្រកាន់ក្នុងសំណុំរឿង ០០៤/០១" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ("[...] សូម្បីក្រៅពីករណីការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ

អង្គបុរេជំនុំជម្រះច្រានចោលការពិចារណានេះ។ ប្រសិនបើលក្ខណៈនៃសេចក្តីសម្រេច អាចថា យកមកពិចារណាជាធាតុផ្សំមួយនៃការការចាត់ថ្នាក់ឯកសារ មែននោះ ខ្លឹមសារនៃសេចក្តីសម្រេច និងផលប៉ះពាល់របស់វាលើផលប្រយោជន៍ គឺជាការចង្អុលបញ្ជាក់កាន់តែប្រសើរជាងមុននៅក្នុងការសម្រេចលើការកំណត់នេះ។ តម្លាភាពនៃកិច្ចដំណើរការ នីតិវិធី មិនអាចត្រូវបានធានានោះទេ ប្រសិននៅពេលការស៊ើបអង្កេតបានបញ្ចប់ហើយនោះ គ្មានការផ្សាយជាសាធារណៈនូវខ្លឹមសារសំខាន់ៗ និងសំអាងហេតុគន្លឹះនៃសេចក្តីសម្រេចស្ថាពរ។ បើធ្វើដូច្នេះ វាពុំសង្គតិភាពអាណត្តិបេសកកម្មនៃ អ.វ.ត.ក និងផលប្រយោជន៍យុត្តិធម៌ជារួមឡើយ។

### *iv. ការកោសលុបចំណុចចាំបាច់អនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង*

៣៨. នៅក្នុងរឿងក្តីនេះ ឈ្មោះបុគ្គលដែលទទួលបានវិធានការការពារអនុលោមតាមវិធាន ២៩(៣) ត្រូវរក្សាការពារបន្តទៀត ហើយមិនត្រូវផ្សាយក្នុងក្របខណ្ឌសាធារណៈនោះឡើយ។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជូនដំណឹងអង្គបុរេជំនុំជម្រះថា សំណើរបស់ជនរងគ្រោះចំនួន ១៤ សុំវិធានការការពារ កំពុងរង់ចាំសេចក្តីសម្រេចនៅក្នុងសំណុំរឿង ០០៤/០១[71] ដែលត្រូវប្រុងប្រយ័ត្នដល់បញ្ហានេះត្រូវបានដោះស្រាយបញ្ចប់។ សហចៅក្រមស៊ើបអង្កេតបានផ្តល់ឈ្មោះបញ្ជីបុគ្គលបន្ថែម ដែលបានទទួលវិធានការការពារនៅក្នុងសំណុំរឿង ០០៤/០១[72]។

### *v. សេចក្តីសន្និដ្ឋាន*

៣៩. អង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាដំណោះស្រាយសាធារណៈ គឺជាវិធីសាស្ត្រសមស្របមួយដើម្បីចូលរួមចំណែកលើគោលការណ៍តម្លាភាពនៃយុត្តិធម៌ កេរដំណែល អ.វ.ត.ក និង

---

នៅពេលសិទ្ធិទាំងនេះអនុវត្តផងដែរនោះ ប៉ុន្តែត្រូវផ្តល់លទ្ធភាពលើវិសាលភាពធំធេងជាងនេះ ចំពោះភាពចាំបាច់ធ្វើយ៉ាងណាឱ្យសាធារណជនដឹងគ្រប់គ្រាន់អំពីការវិវឌ្ឍន៍នីតិវិធី")។

[71] *សូមមើល* អនុស្សារណៈរបស់អង្គភាព WESU និងឧបសម្ព័ន្ធ D309/2/1/5/1.2។

[72] *សូមមើល* អនុស្សារណៈរបស់អង្គភាព ក.ស.ច.ស WESU និងឧបសម្ព័ន្ធ D309/2/1/6/1.2។

គោលដៅសំខាន់គឺការអប់រំ និងការស្វែងរកយុត្តិធម៌[73]។ ស្របតាមការអនុវត្តរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាមានភាពចាំបាច់ត្រូវកម្រិតការកោសលុបនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ត្រឹមតែឈ្មោះ និងអាសយដ្ឋានបុគ្គលដែលស្ថិតក្រោមវិធានការការពារអនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង ឬ ចាំបាច់ឱ្យមានការការពារបែបនោះដល់ពួកគេទេ។

៤០. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ព្រមតាមសំណើសុំធ្វើចំណាត់ថ្នាក់ដីកាដំណោះស្រាយ (សំអាងហេតុ) ឡើងវិញ ហើយប្រកាសថា បណ្តឹងឧទ្ធរណ៍នេះចាត់ទុកជាឥតបានការ។

**២. ការធ្វើចំណាត់ថ្នាក់ដីកាសម្រេចដែលរងការជំទាស់ និងសេចក្តីសន្និដ្ឋានពាក់ព័ន្ធឡើងវិញ**

៤១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវី យល់ស្របតាមសំណើសុំធ្វើចំណាត់ថ្នាក់ដីកាសម្រេចដែលរងការជំទាស់ និងសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ជាសាធារណៈឡើងវិញ[74]។ យោងតាមសំអាងហេតុដូចគ្នាខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា វាមានភាពសមស្របក្នុងការធ្វើចំណាត់ថ្នាក់ជាសាធារណៈឡើងវិញចំពោះដីកាបង្គាប់ដែលរងការជំទាស់ បណ្តឹងឧទ្ធរណ៍ ចម្លើយតប និងការឆ្លើយតប ប៉ុន្តែត្រូវកោសលុបតិចតួចប៉ុណ្ណោះលើឈ្មោះ និងអាសយដ្ឋានបុគ្គលដែលស្ថិតនៅក្រោមវិធានការការពារអនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង ឬ ចាំបាច់ឱ្យមានការការពារបែបនោះដល់ពួកគេ។

**យោងតាមសំអាងហេតុទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

[73] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា កថាខណ្ឌ ២។

[74] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២ កថាខណ្ឌ ៦៤, ៦៦។ ចម្លើយតប កថាខណ្ឌ ៤ និងទំព័រ ២៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

- **យល់ព្រមតាម** សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ។

- **ប្រកាសចាត់ទុក** បណ្តឹងឧទ្ធរណ៍នេះ ឥតបានការ។

- **បង្គាប់** ការិយាល័យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3) ជាឯកសារសាធារណៈ ក្នុងរយៈពេលប្រាំពីរថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលដីកានេះ។

- **បង្គាប់** ការិយាល័យសហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចដែលរងការជំទាស់ (ឯកសារ D309/3) ជាឯកសារសាធារណៈ ក្នុងរយៈពេលប្រាំពីរថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលដីកានេះ។

- **ណែនាំ** ការិយាល័យសហចៅក្រមស៊ើបអង្កេត កោសលុបឈ្មោះ និងអាសយដ្ឋានបុគ្គលដែលទទួលបានវិធានការការពារ អនុលោមតាមវិធាន ២៩(៣) ឬ ចាំបាច់ឱ្យមានការការពារបែបនោះដល់ពួកគេ។

- **បង្គាប់** សហព្រះរាជអាជ្ញាអន្តរជាតិ ដាក់បណ្តឹងឧទ្ធរណ៍ (ឯកសារ D309/2/1/2) និងការឆ្លើយតប (ឯកសារ D309/2/1/4) ជាឯកសារសាធារណៈ ក្នុងរយៈពេល ប្រាំពីរថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលដីកានេះ។

- **បង្គាប់** សហមេធាវី ដាក់សំណៅចម្លើយតបរបស់ខ្លួន (ឯកសារ D309/2/1/3) ជាឯកសារសាធារណៈ ក្នុងរយៈពេលប្រាំពីរថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលដីកានេះ។

- **ណែនាំ** សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវី កោសលុបឈ្មោះ និងអាសយដ្ឋានបុគ្គលដែលទទួលបានវិធានការការពារ អនុលោមតាមវិធាន ២៩(៣) ឬ ចាំបាច់ឱ្យមានការការពារបែបនោះដល់ពួកគេ ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០១៨**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** Olivier BEAUVALLET **នំយ ថុល** Kang Jin BAIK **ហួត វុទ្ធី**